ANNA & ASSOCIATES
Law Office

# ព្រឹត្តិបត្រគតិយុត្តខ្លីៗប្រចាំខែ
# ខែកុម្ភៈ ឆ្នាំ ២០២២
# ភាគ ២៧

## ការរស់នៅបែបអនីតិសង្វាស

### ១. តើអ្វីទៅជាអនីតិសង្វាស ?

ក្រោយពីធ្វើការបកស្រាយទៅលើការរៀបអាពាហ៍ពិពាហ៍ក្នុងព្រឹត្តិបត្រគតិយុត្តខែមុនរួចមក យើងបានយល់ដឹងបន្ថែមទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍ដែលត្រឹមត្រូវស្របទៅតាមផ្លូវច្បាប់។ ផ្ទុយទៅវិញ ក្នុងស្ថានភាពដែលបុរស-នារីរួមរស់ជាមួយគ្នាដូចប្ដី-ប្រពន្ធដោយមិនបានបំពេញតាមលក្ខខណ្ឌច្បាប់ទេនោះ នឹងត្រូវចាត់ទុកថាជា **ចំណងអនីតិសង្វាស**។ ហេតុនេះ តើអ្វីទៅជាចំណងអនីតិសង្វាស ?

ចំណងអនីតិសង្វាស ជាចំណងដែលកើតមានឡើងនៅពេលបុរស-នារីធ្វើការរួមរស់ជាមួយគ្នាដូចជាប្ដី-ប្រពន្ធ ដោយមានជីវភាព និងដំណើរជីវិតរួមគ្នា សម្ព័ន្ធភាពផ្លូវភេទ ទ្រព្យសម្បត្តិ និងលំនៅរួមគ្នា ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ឱ្យស្របទៅតាមផ្លូវច្បាប់ ឬក៏ប្រារព្ធឡើងទៅតាមប្រពៃណីទំនៀមទម្លាប់តែប៉ុណ្ណោះ។

ឧទាហរណ៍ ៖ បុរស ក បានរៀបអាពាហ៍ពិពាហ៍ជាមួយនារី ខ ដោយពិធីមង្គលការប្រារព្ធឡើងតាមបែបប្រពៃណី និងមានត្រឹមតែឪពុកម្ដាយចាស់ទុំបានចូលរួមដឹងលឺតែប៉ុណ្ណោះ។ ក្រោយពេលពិធីរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណីនោះបានបញ្ចប់ ប្ដី-ប្រពន្ធ មិនបានធ្វើការចុះនូវសំបុត្រអាពាហ៍ពិពាហ៍ជាមួយមន្ត្រីអាត្រានុកូលដ្ឋាននោះទេ។ ជាក់ស្ដែងការរៀបអាពាហ៍ពិពាហ៍ ឬការរួមរស់បែបនេះ គឺមិនត្រូវបានទទួលស្គាល់ដោយច្បាប់នោះទេ ហើយវាក៏អាចបង្កនូវផលប៉ះពាល់ដល់ផលប្រយោជន៍អនីតិសង្វាសជនផងដែរ។ ជាពិសេសក្នុងពេលមានការផ្ដាច់ចំណងអនីតិសង្វាសតែម្ដង ដែរនឹងត្រូវយកមកបកស្រាយនៅក្នុងព្រឹត្តិបត្រគតិយុត្តនៅភាគបន្ទាប់។

### បច្ចុប្បន្នភាពគតិយុត្ត

*ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ បានចេញសេចក្ដីជូនដំណឹង លេខ ០០១ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២ ស្ដីពី ការដាក់ឱ្យអនុវត្តការត្រួតពិនិត្យ និងបញ្ជាក់សំណង់ក្នុងស្មារតីដាក់ឱ្យម្ចាស់សំណង់ អ្នកអភិវឌ្ឍអចលនវត្ថុ និងអ្នកអភិវឌ្ឍលំនៅឋាន ត្រូវរកអ្នកវិជ្ជាជីវៈ ឬក្រុមហ៊ុនពិនិត្យ និងបញ្ជាក់សំណង់ ដែលមានអាជ្ញាបណ្ណផ្ដល់ដោយក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីត្រួតពិនិត្យ និងចេញលិខិតបញ្ជាក់អនុលោមភាពនៃគម្រោងប្លង់ ការងារសោងសង់រុះរើសំណង់របស់ខ្លួនតាមបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានដទៃទៀត មុននឹងធ្វើការដាក់ពាក្យស្នើសុំ លិខិតអនុញ្ញាតសាងសង់ រុះរើ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងវិញ្ញាបនបត្រប្រើប្រាស់សំណង់។*

### ២. តើមានមូលហេតុអ្វីខ្លះដែលអាចនាំឱ្យមានការរួមរស់ជាអនីតិសង្វាសនៅក្នុងសង្គមបច្ចុប្បន្ន ?

ស្របតាមការមើលឃើញនៅក្នុងទិដ្ឋភាពសង្គមជាក់ស្ដែងមានមូលហេតុមួយចំនួន ដែលអាចនាំឱ្យបុរស-នារីរួមរស់ជាមួយគ្នាតាមបែបអនីតិសង្វាសនៅក្នុងសង្គមនាពេលបច្ចុប្បន្ននេះ៖

- ដោយភាគីម្ខាងមានចំណងអាពាហ៍ពិពាហ៍ចាស់មិនទាន់រំលាយ ឬភាគីម្ខាងជាអនីតិជនដែលមិនទាន់ដល់នីតិភាពក្នុងការរៀបអាពាពិហ៍ពាហ៍បាន
- ការយល់ឃើញរបស់បុរស-នារីផ្ទាល់ដោយមិនចង់មាននូវចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ មិនចង់មានការផ្លាស់ប្ដូរត្រកូលក៏ដូចជាដើម្បីបើកសិទ្ធិសេរីភាពក្នុងការលែងលះនៅពេលដែលភាគីទាំងទាំងសងខាងរស់នៅមិនចុះសម្រុង ដោយហេតុថាការលែងលះមិនតម្រូវឱ្យឆ្លងកាត់នីតិវិធីផ្លូវច្បាប់ដូចអាពាហ៍ពិពាហ៍ស្របច្បាប់ឡើយ
- កត្តាសមីខ្លួនមិនយល់ដឹងអំពីលក្ខខណ្ឌដើម្បីទទួលបានអាពាហ៍ពិពាហ៍ស្របច្បាប់ និងមិនបានអនុវត្តតាមច្បាប់ដោយយល់ឃើញថានីតិវិធីក្នុងការចុះសំបុត្រអាពាហ៍ពិពាហ៍មានលក្ខណៈស្មុគស្មាញ ឬភាគីទាំងសងខាងយល់ឃើញថាការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី មានលក្ខណៈសំខាន់ជាងការចុះសំបុត្រអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់
- កត្តាប្ដី-ប្រពន្ធដែលបានរួមរស់ជាមួយគ្នាមុនពេលដែលច្បាប់កំណត់នូវការចុះសំបុត្រអាពាហ៍ពិពាហ៍តាំងពីដើម ឬមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ក្រោយសេចក្ដីណែនាំ ស្ដីពីការចុះសៀវភៅអាត្រានុកូលដ្ឋានឱ្យមាននិរន្តភាពក្រោយយុទ្ធនាការណ៍ចុះសៀវភៅអាត្រានុកូលដ្ឋានចល័ត ចុះថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០០៧ ក្នុងចំណុចទី ៤ ធំ។

***ការបដិសេធ:*** *ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្ដល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្ដោត សំខាន់ ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្ដល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*

## ៣. តើចំណងអនីតិសង្វាសអាចបង្កជាផលវិជ្ជមាន និងផលអវិជ្ជមានអ្វីខ្លះ?

ដោយហេតុថាមិនមានបទដ្ឋានគតិយុត្ត ក៏ដូចជាបទប្បញ្ញត្តិច្បាប់ចែងច្បាស់អំពីចំណងអនីតិសង្វាស។ ហេតុនេះផលវិជ្ជមាន និងផលអវិជ្ជមាន ដែលកើតមានឡើងនៃចំណងអនីតិសង្វាស គឺផ្អែកទៅលើការសង្កេតមើលឃើញផ្ទាល់នៅក្នុងសង្គមជាក់ស្តែងនាពេលបច្ចុប្បន្ននេះដោយមានដូចជា៖

| ផលវិជ្ជមាន | ផលអវិជ្ជមាន |
|---|---|
| • មានភាពងាយស្រួលក្នុងការបង្កើត និងផ្តាច់ដោយមិនទាមទារនូវនីតិវិធីស្មុគស្មាញដូចទៅនឹងជាអាពាហ៍ពិពាហ៍ស្របច្បាប់នោះទេ<br>• អាចរស់នៅជាមួយគ្នាដោយងាយស្រួល ចំណេញពេលវេលា និងមិនចំណាយច្រើនទៅលើការរៀបអាពាហ៍ពិពាហ៍<br>• ភាគីអនីតិសង្វាសម្ខាង អាចធ្វើការទាមទារសំណងខូចខាតដែលកើតមានឡើងដោយមូលហេតុមរណៈភាព នៃភាគីអនីតិសង្វាសម្ខាងទៀត ដែលមានករណីកិច្ចផ្តល់អាហារកិច្ច។ | • ភាគីម្ខាងនៃអនីតិសង្វាសជនអាចបង្កើតចំណងអនីតិសង្វាសផ្សេងទៀតបានដោយមិនខុសច្បាប់ ដោយផ្ទុយអំពីច្បាប់ស្តីពីឯកពន្ធភាព មាត្រា ២ ដែលអនុញ្ញាតឱ្យភាគីប្តី ប្រពន្ធគោរពតាមគោលការណ៍ឯកពន្ធភាពត្រូវមានប្តីមួយប្រពន្ធមួយ<br>• អនីតិសង្វាសជនមិនមែនជាសន្តតិជនរបស់ភាគីអនីតិសង្វាសជនម្ខាងទៀតទេ<br>• កូនដែលកើតចេញពីឪពុកម្តាយជាអនីតិសង្វាស មានអំណាចមេបាទោល ដោយមានតែម្តាយទេដែរជាអ្នកទទួលបានសិទ្ធិជាអាណាព្យាបាល<br>• គូភាគីអនីតិសង្វាសអាចធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តី-ប្រពន្ធ ក៏ប៉ុន្តែមិនអាចមានអានុភាពដូចទ្រព្យសម្បត្តិប្តី-ប្រពន្ធស្របច្បាប់នោះទេ ដោយហេតុថាទ្រព្យសម្បត្តិនោះមិនបានចុះបញ្ជីដូច្នេះមិនអាចយកទៅតតាំងជាមួយតតិយជនបានឡើយ។ |

យោងទៅតាមការបកស្រាយខាងលើ ការរស់នៅក្នុងនាមជាអនីតិសង្វាសជន គឺមានទាំងផលវិជ្ជមាន និងផលអវិជ្ជមាន។ យ៉ាងណាក្តី ដើម្បីទទួលបាននូវការការពារផលប្រយោជន៍របស់ខ្លួន ក៏ដូចជាកូនរបស់ខ្លួនតាមផ្លូវច្បាប់ បុរស-នារីគួរជ្រើសរើសយកចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ដោយធ្វើការចុះនូវសំបុត្រអាពាហ៍ពិពាហ៍ និងចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធឱ្យត្រឹមត្រូវ។

**ទំនាក់ទំនងមកកាន់៖**

**ការិយាល័យមេធាវី អេណា និងសហការី**
**គេហទំព័រ**: www.anna-associates.com
**អ៊ីម៉ែល**: info@anna-associates.com
**លេខទូរស័ព្ទ**: (+៨៥៥) ៩៩ ៨៨៨ ៧៣៧

**អាសយដ្ឋានការិយាល័យ**: អាគារលេខ២៣៤ ជាន់ទី៧ មហាវិថីម៉ៅសេទុង សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

*__ការបដិសេធ:__ ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្តល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្តោត សំខាន់ ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្តល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*

***<u>ការបដិសេធ:</u>*** *ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្តល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្តោត សំខាន់ ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្តល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់ ។*